# ព្រះរាជក្រឹត្យ

នស/រកត/០៩២៣/ ២១៥៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

## ត្រាស់បង្គាប់

**មាត្រា ១.**_

ត្រូវបានកែសម្រួលមាត្រា២ និងមាត្រា១៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើត **“គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ”** ដូចខាងក្រោម៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ២._ (ថ្មី)**

គ.ជ.អ.ប. មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៣. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៤. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ជាអនុប្រធាន |
| ៥. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាអនុប្រធាន |
| ៦. ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាអនុប្រធាន |
| ៧. ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ០១រូប | ជាអនុប្រធានអចិន្ត្រៃយ៍ |
| ៨. រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ជាសមាជិក |
| ៩. រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | ជាសមាជិក |
| ១០. រដ្ឋមន្ត្រីក្រសួងផែនការ | ជាសមាជិក |
| ១១. រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ជាសមាជិក |
| ១២. រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ១៣. រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ១៤. រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ជាសមាជិក |
| ១៥. រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល | ជាសមាជិក |
| ១៦. រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ជាសមាជិក |
| ១៧. រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ១៨. រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ជាសមាជិក |
| ១៩. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ជាសមាជិក |
| ២០. រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | ជាសមាជិក |
| ២១. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០២រូប | ជាសមាជិក |
| ២២. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប | ជាសមាជិក |
| ២៣. រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ០១រូប | ជាសមាជិក |
| ២៤. តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ០១រូប | ជាសមាជិក |
| ២៥. ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. | ជាសមាជិក។ |

អនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. ត្រូវចាត់តាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។ រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដែលជាសមាជិកនៃ គ.ជ.អ.ប. ត្រូវចាត់តាំងដោយរដ្ឋមន្ត្រី និងប្រធានស្ថាប័នសាមី។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ក្រៅពីសមាជិកខាងលើនេះ គ.ជ.អ.ប. អាចស្នើបន្ថែមសមាជិកជារដ្ឋមន្ត្រី ឬប្រធានស្ថាប័ននៃក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលតាមការចាំបាច់។

សមាជិកម្នាក់ៗត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន គ.ជ.អ.ប. ។ ក្នុងករណីមិនអាចចូលរួមប្រជុំបាន សមាជិកនោះអាចចាត់តាំងតំណាងមួយរូបដែលមានសិទ្ធិសម្រេចដើម្បីចូលរួមក្នុងកិច្ចប្រជុំ។

គ.ជ.អ.ប. អាចអញ្ជើញរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន ឬអាជ្ញាធរ ឬអ្នកពាក់ព័ន្ធផ្សេងៗទៀតឱ្យចូលរួមកិច្ចប្រជុំតាមការចាំបាច់។

**មាត្រា ១៨._ (ថ្មី)**

គ.ជ.អ.ប. ត្រូវមានលេខាធិការដ្ឋានមួយស្ថិតនៅក្នុងទីស្តីការក្រសួងមហាផ្ទៃ។

លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវដឹកនាំដោយប្រធានមួយ(០១)រូប ជារដ្ឋលេខាធិការក្រសួងមហាផ្ទៃ អមដោយអនុប្រធានមួយចំនួនមានឋានៈស្មើអនុរដ្ឋលេខាធិការជាជំនួយការដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមរយៈសេចក្តីស្នើសុំពីប្រធាន គ.ជ.អ.ប.។

លេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបង្កើតឱ្យមានអង្គភាពនានាដែលកំណត់ដោយអនុក្រឹត្យ។

អង្គភាពនីមួយៗនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវគ្រប់គ្រងដោយប្រធានមួយ(០១)រូប មានឋានៈស្មើអគ្គនាយកដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យ និងមានអនុប្រធានមួយចំនួនមានឋានៈស្មើអគ្គនាយករងជាជំនួយការ ដែលត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា ពីរ._**

ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើត **"គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ"** ត្រូវបានធ្វើការកែសម្រួលដោយបន្ថែមមាត្រា១២ (ស្ទួន) ដូចខាងក្រោម៖

**មាត្រា ១២._ (ស្ទួន)**

អនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. មានភារកិច្ចជួយប្រធាន គ.ជ.អ.ប. ក្នុងការសម្របសម្រួលជាមួយអនុគណៈកម្មាធិការនៃ គ.ជ.អ.ប. ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា ដើម្បីធានាដល់ការបំពេញបេសកកម្មរបស់ គ.ជ.អ.ប. ឱ្យមានប្រសិទ្ធភាព។

ប្រធាន គ.ជ.អ.ប. អាចប្រគល់ភារកិច្ចជាក់លាក់ដល់អនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. តាមការចាំបាច់។

**មាត្រា បី._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។



**មាត្រា ប្អូន.**_

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសមាសភាពដូចមានចែងក្នុងមាត្រា២(ថ្មី) ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃអង្គារ ៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣
**ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

នស/រកត/០៩២៣/៩៥០

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**